អ គ្គិ ស នី ក ម្ពុ ជា

លេខ : ៤៧៣៧ សដលា.អក.អ៨

# សេចក្តីជូនដំណឹង

**អគ្គិសនីកម្ពុជា** មានកិត្តិយសសូមទូលថ្វាយ និងជម្រាបជូនសម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី ដែលជាប្រធានក្រុមហ៊ុន សណ្ឋាគារ សិប្បកម្ម រោងចក្រ សហគ្រាស កសិដ្ឋាន ទាំងឡាយ ដែលបានប្រើប្រាស់ និងមានបំណងចង់ប្រើប្រាស់ថាមពលអគ្គិសនី ភ្ជាប់ពីបណ្តាញតង់ស្យុងមធ្យម (22KV) ជ្រាបថា ៖ យោងលើសេចក្តីសម្រេចរបស់អាជ្ញាធរអគ្គិសនីកម្ពុជា លេខ៣២៩ ស.រអអក ចុះថ្ងៃទី ២៨ ខែសីហា ឆ្នាំ២០១៤ បានកំណត់បញ្ជីថ្លៃលក់អគ្គិសនី *តាមពេលវេលាប្រើប្រាស់ (Time of Use)* សម្រាប់អ្នកប្រើប្រាស់ ដែលទិញលើតង់ស្យុងមធ្យមរបស់អគ្គិសនីកម្ពុជា តាមអត្រាថ្លៃលក់ លក្ខខណ្ឌភ្ជាប់ និងពេលវេលាប្រើប្រាស់ ដូចក្នុង តារាងខាងក្រោម ៖

| លក្ខខណ្ឌ | អត្រាថ្លៃលក់ | |
|---|---|---|
| | ប្រើប្រាស់នៅម៉ោង 07:00-21:00 | ប្រើប្រាស់នៅម៉ោង 21:00-07:00 |
| ភ្ជាប់ពីខ្នាបទីទាវរចន្តតង់ស្យុងមធ្យម របស់អនុស្ថានីយបណ្តាញជាតិ | 13.90 ¢ USD/kWh | 9.50 ¢ USD/kWh |
| ភ្ជាប់ពីបណ្តាញបញ្ជូនវេង ចេញពីអនុស្ថានីយបណ្តាញជាតិ | 17.90 ¢ USD/kWh | 14.00 ¢ USD/kWh |
| ភ្ជាប់ពីបណ្តាញតង់ស្យុងមធ្យម របស់ប្រព័ន្ធចែកចាយ រាជធានីភ្នំពេញ | 19.00 ¢ USD/kWh | 15.00 ¢ USD/kWh |
| ភ្ជាប់ពីខ្នាបទីទាវរចន្តតង់ស្យុងមធ្យម របស់អនុស្ថានីយ ក្នុងរាជធានីភ្នំពេញ | 17.50 ¢ USD/kWh | 13.50 ¢ USD/kWh |

អាស្រ័យហេតុនេះ សូមសម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី ជ្រាបជាព័ត៌មាន និងក្នុងករណីមានចំណាប់អារម្មណ៍ ឬមានសំនួរផ្សេងៗទាក់ទងនឹងការផ្តល់ជូនខាងលើនេះ សូមធ្វើការទំនាក់ទំនងមកការិយាល័យ លក់ និងម៉ាឃែតធីង នៃនាយកដ្ឋានអាជីវកម្មចែកចាយ អគ្គិសនីកម្ពុជា ។

លេខទូរស័ព្ទទំនាក់ទំនង 023 722 504 - 016 444 944

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ២០១៤

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**

**ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា**

ELECTRICITE DU CAMBODGE

**កែវ_រតនៈ**